**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមន្ទីរសារការី នីតិនិរន្តរ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១** .-

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី នីតិនិរន្តរ៍** (Nitei Niron Notary Public) នៃព្រះរាជាណាចក្រកម្ពុជា សរសេរកាត់ជាភាសាខ្មែរ “ **ម.ស.ន.ន** ” និងសរសេរកាត់ជាភាសាអង់គ្លេស “ N&N Notary Public ” ។



www.pheakdeylaw.com.kh

**មាត្រា ២ .-**

មន្ទីរសារការី នីតិនិន្នូ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ៩អា ផ្លូវ១៨៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ៣ .-**

មន្ទីរសារការី នីតិនិន្នូ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- តាក់តែងកិច្ចសន្យា កិច្ចព្រមព្រៀងនានា លិខិតស្នាមគតិយុត្តផ្សេងៗ និងធ្វើការប្រថាប់ត្រាបញ្ជាក់ពីហត្ថលេខា និងស្នាមមេដៃរបស់គូភាគី ដើម្បីបំពេញបន្ទាល់លក្ខណៈតាមផ្លូវច្បាប់
- ពិគ្រោះប្រឹក្សាយោបល់នូវចំណោទច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យគ្រួសារ ចលនវត្ថុ អចលនវត្ថុ ពាណិជ្ជកម្ម និងវិនិយោគ
- ធ្វើការបញ្ជាក់នូវភាពពិតប្រាកដនូវឯកសារថតចម្លងផ្សេងៗ
- ធ្វើការតាក់តែងនូវមតកសាសន៍ និងលិខិតយថាភូតទាំងឡាយ ត្រឹមត្រូវតាមទម្រង់នៃក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ព្រមទាំងក្រម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- និងកិច្ចការផ្សេងៗទៀតដែលស្ថិតនៅក្នុងវិសាលភាពនៃការប្រកបវិជ្ជាជីវៈសារការី ស្របទៅតាមក្រម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤ .-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាព មន្ទីរសារការី នីតិនិន្នូ ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ការធានាទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយ មន្ទីរសារការី នីតិនិន្នូ ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងសោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តិរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមអនុក្រឹត្យនេះ។

**មាត្រា ៥ .-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១. **លោក ស៊ិន សំណាង** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារការី នីតិនិន្នូ

២. **លោកស្រី គួន លីនណា** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី នីតិនិន្នូ

៣. **លោក ផូ សុធាផល** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី នីតិនិន្នូ

ក្នុងករណីចាំបាច់ មន្ទីរសារការី នីតិនិន្នូ អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។



www.pheakdeylaw.com.kh

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com.kh